រាជបណ្ឌិត្យសភាកម្ពុជា

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១

## ភាគទី៧ - វគ្គទី៥

អត្ថបទចងក្រងដោយៈ លោកស្រី **ស៊ិន ច័ន្ទអមរា**
មន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា



ពិធីសម្ពោធ«វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១» ក្រោមអធិបតីភាព

ព្រះបាទសម្តេចស៊ីសុវត្ថិ និងរេស៊ីដង់ជាន់ខ្ពស់បារាំង[1]

---

[1] ប្រភពរូបថត : https://sopheak.wordpress.com/2015/11/30។

បន្ទាប់ពីលោករេស៊ីដង់ជាន់ខ្ពស់បារាំងបានបញ្ចប់នូវសុន្ទរកថារបស់លោករួចរាល់ ដូចបានបង្ហាញនៅក្នុងភាគទី៧ វគ្គទី៤ នៅក្នុងភាគទី៧ វគ្គទី៥នេះគឺសង្កថា[2]របស់ព្រះបាទសម្ដេចស៊ីសុវត្ថិ។ សូមបញ្ជាក់ថា ទោះបីជាព្រះអង្គមានព្រះជន្មច្រើន ហើយទើបតែងើបពីអាពាធខ្លាំងក៏ដោយ ក៏ព្រះអង្គនៅតែយាងមកជាអធិបតីនៅក្នុងពិធីបុណ្យនេះ ដោយបានធ្វើសេចក្ដីអធិប្បាយខ្លីៗ និងមានសេចក្ដីកត់ត្រា ដែលមានខ្លឹមសារដើម និងការកែសម្រួលមួយចំនួនដូចខាងក្រោមៈ

**៧-៣-សង្កថារបស់ព្រះបាទសម្ដេចស៊ីសុវត្ថិ**[3]

ជម្រាបលោក ឡឺរេស៊ីដង់ សុប៉េរីយ៉េរ ជ្រាប។

សេចក្ដីលើកតម្កើងអ្នកមានចិត្តទាហានក្លាហាន ដែលទ្រង់ទើបបានស្ដាប់ឈ្មោះដែលគេហៅអម្បាញ់មិញនោះ ជាការមួយដែលត្រូវគង់នៅជានិច្ចកាលតរៀងទៅ ដោយមានសេចក្ដីទំនុកបម្រុងឈឺឆ្អាលពីរាជការគូវែរណើម៉ង់បារាំងសែស[4]និងពីជាងរចនាឈ្មោះលោកឌូក្វាំង (Ducoing) ដែលបានសាងវិមានទុកសម្គាល់ជាកេរទៅមុខរកអ្វីនឹងធៀបពុំបាន។

ការដែលបានរៀបចំពិធីបុណ្យយ៉ាងសម្បើម ដោយមានការរៀបចំតាក់តែងយ៉ាងសំខាន់ មានការហែក្បួនយ៉ាងមាំមួន និងមានទាំងមនុស្សគ្រប់ភាសាមកពីខេត្តក្រៅដែលនៅឆ្ងាយជាងគេនោះ ឃើញថាការទាំងអស់នេះនាំឱ្យរំឭកដោយរំជួលក្នុងចិត្តដល់អស់ទាំងអ្នកមានថ្វីដៃ ដែលបានបាត់បង់ជីវិតដោយបានជួយការពារព្រះមហានគរអាណាព្យាបាល[5] ដែលមានចិត្តសប្បុរសជ្រះថ្លានឹងតយុទ្ធជាមួយនិងព្រះមហានគរសម្ព័ន្ធមិត្តទាំងប៉ុន្មានដើម្បីឱ្យរួចពីសេចក្ដីទុក្ខ បានសុខជាឯកចិត្តតរៀងទៅ។

ទ្រង់ព្រះករុណាមានព្រះរាជហឫទ័យ រំជួលជាខ្លាំងពន្លឹកបើកាលណាទ្រង់នឹកដល់ទៅទីកន្លែងចម្បាំង ដែលសេនាទាហានរបស់ព្រះករុណា ព្រមទាំងសេនាទាហានទិសខាងលិចបានចូលច្បាំងតយុទ្ធអំពីដំណើរជាមួយគ្នា ហើយបានយកឈាមទៅតស៊ូនាំឱ្យនគរក្រុងកម្ពុជានិងព្រះមហានគរបារាំងសែសមានសេចក្ដីរឹតតែមេត្រីស្និទ្ធស្នាល ទៅវិញទៅមកថែមទៀត។

---

[2] សង្កថា(Allocution) គឺការថ្លែងសេចក្ដីមាត់ទទេ វចនានុក្រម ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧ ទំព័រ១២៣៤។

[3] បុន្យ៍ឆ្លងវិមានដែរសាងក្នុងក្រុងក័ម្វុជាធិប្តី, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥ ទំព័រ៩៥-៩៧។

[4] គូវែរណើម៉ង់បារាំងសែស(Gouvernement français) គឺរដ្ឋាភិបាលបារាំង។

[5] ព្រះមហានគរអាណាព្យាបាល គឺប្រទេសបារាំង។

អាណាប្រជានុរាស្ត្ររបស់ទ្រង់មានអំណររីករាយ ដោយបានឃើញក្នុងពិធីបុណ្យថ្ងៃនេះនូវវិមានយ៉ាងសំខាន់សម្រាប់ទុករំឭកគុណដល់អ្នកដែលបានតយុទ្ធដោយសុចរិតស្មោះត្រង់ក្នុងចម្បាំងនេះ។ ព្រះករុណាមានសេចក្តីសោមនស្ស ដោយទ្រង់បានយល់ថាការដែលធ្វើដូច្នេះនេះជាតម្រូវនឹងព្រះរាជហឫទ័យដែលចង់ឱ្យសំណាងនៃនគរយើងជាប់រួបរួមគ្នាជាមួយនឹងសំណាងនៃនគរបារាំងសែស ជានិច្ចកាលតរៀងទៅ។

ព្រះអង្គបានថ្លែងអំណរគុណចំពោះព្រះមហានគរជាអាណាព្យាបាល ដែលបានកសាងវិមាននេះនាំឱ្យក្រុងភ្នំពេញមានសេចក្តីថ្កើងរុងរឿងមានកេរ្តិ៍ឈ្មោះពីរោះល្អ ហើយជាការគោរពស្គាល់គុណយ៉ាងខ្ពស់បំផុត ដល់អស់អ្នកដែលមានគុណបំណាច់ថ្វីដៃ ដែលបានបាត់បង់ជីវិតក្នុងគ្រាចម្បាំងធំនេះ។

(សូមរង់ចាំអានភាគបន្ត...)